ខ្ញុំ និង Dell របស់ខ្ញុំ

សម្រាប់កុំព្យូទ័រ Inspiron, G-Series, XPS និង Alienware

January 2021
ការបិទប្រូម៉ូសិញ A08

DELL EMC

កំណត់ចំណាំ ការប្រុងប្រយ័ត្ន និងការព្រមានប្រាប់

ចំណាំ: កំណត់ចំណាំបង្ហាញពីព័ត៌មានសំខាន់ដែលជួយអ្នកដើម្បីប្រើប្រាស់ផលិតផលរបស់អ្នកឱ្យកាន់តែប្រសើរឡើង។

ប្រយ័ត្ន: **ការប្រុងប្រយ័ត្នបង្ហាញនូវការខូចខាតដែលអាចកើតមានលើហាដវែរ ឬការបាត់បង់ទិន្នន័យ ហើយប្រាប់ពីរបៀបដើម្បីជៀសវាងពីបញ្ហានេះ។**

ការព្រមាន: **សារព្រមានបង្ហាញនូវសក្តានុពលនៃការខូចខាតទ្រព្យសម្បត្តិ របួសផ្នែករាងកាយ ឬសេចក្តីស្លាប់។**

© 2011-2021 Dell Inc. ឬក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន។ រក្សាសិទ្ធគ្រប់យ៉ាង។ Dell, EMC និងនិមិត្តសញ្ញាពាណិជ្ជកម្មផ្សេងទៀតគឺជានិមិត្តសញ្ញាពាណិជ្ជកម្មរបស់ក្រុមហ៊ុន Dell Inc. ឬក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន។ និមិត្តសញ្ញាពាណិជ្ជកម្មផ្សេងទៀតអាចជានិមិត្តសញ្ញាពាណិជ្ជកម្មនៃម្ចាស់កម្មសិទ្ធិរៀងខ្លួន។

មាតិកា

ជំពូក 1: ការរៀបចំម៉ាស៊ីនកុំព្យូទ័ររបស់អ្នក 7

ការភ្ជាប់អ៊ីនធឺណិត 7

ការភ្ជាប់ទៅអ៊ីនធឺណិតដោយប្រើប្រាស់ LAN 7

ការភ្ជាប់ទៅអ៊ីនធឺណិតដោយប្រើ WLAN 7

ភ្ជាប់ទៅអ៊ីនធឺណិតដោយប្រើ WWAN 8

ការរៀបចំអូឌីយ៉ូ 8

ការកំណត់រចនាសម្ព័ន្ធអូឌីយ៉ូ 5.1 និង 7.1 8

ការភ្ជាប់ឧបករណ៍បំពងសំឡេង 5.1 9

ការតភ្ជាប់ឧបករណ៍បំពងសំឡេង 7.1 10

ការរៀបចំម៉ាស៊ីនព្រីនរបស់អ្នក 10

Windows 10 និង 8.1 10

Windows 7 11

ការរៀបចំវិបខេម 11

វិបខេមបញ្ចូលគ្នា 11

វិបខេមខាងក្រៅ 11

ការរៀបចំប៊ីធូស 11

ការភ្ជាប់ម៉ូនីទ័រច្រើន 11

Windows 10 11

Windows 8 12

Windows 7 12

ជំពូក 2: អំពីកុំព្យូទ័ររបស់អ្នក 13

អាដាប់ទ័រថាមពល 13

ថ្ម 13

ថ្មគ្រាប់សំប៉ែត 14

បន្ទះប៊ិះ 14

អេក្រង់ 14

អេក្រង់ប៊ិះ 14

3D 14

ការបង្ហាញឥតខ្សែ 14

កាមេរ៉ា 15

វិបខេម 15

កាមេរ៉ា 3D 15

កាមេរ៉ា Intel RealSense 3D 15

អេក្រង់ឥតខ្សែ 15

ក្តារចុច (ប៊ីបត) 15

ក្តារចុចខាងក្រៅ 15

ក្តារចុចលើអេក្រង់ 16

ប្រភេទនៃការភ្ជាប់ក្តារចុច 16

ស្លាកសេវាកម្ម និងលេខកូដសេវាកម្មរបស់ 17

ស្វែងរកទីតាំងស្លាកនៅលើកុំព្យូទ័ររបស់អ្នក 17

ឧបករណ៍ផ្ទុក 17

ឧបករណ៍ផ្ទុកខាងក្នុង 17

ឧបករណ៍ផ្ទុកចល័តដែលអាចដកចេញបាន 17

ម៉ូឌុលអង្គចងចាំ 19
ផ្ទាំងប្រព័ន្ធ 20
សំណុំបន្ទះសៀគ្វីតូច 20
អង្គដំណើរការ 20
កង្ហារកុំព្យូទ័រ 21
កន្លែងទទួលកំដៅ 21
ការការពារកំដៅ 21
កាតវីដេអូ 21
កម្មវិធីទូរទស្សន៍ 21
ឧបករណ៍បំពងសំឡេង 22
2.1 អូឌីយ៉ូ 22
អូឌីយ៉ូ 5.1 22
7.1 អូឌីយ៉ូ 23
វិបខេម 23
បណ្តាញ 23
Local Area Network (បណ្តាញតំបន់មូលដ្ឋាន) 23
Wireless Local Area Network (បណ្តាញក្នុងតំបន់ឥតខ្សែ) 23
Wireless Wide Area Network (បណ្តាញតំបន់ធំទូលាយឥតខ្សែ) 23
Wireless Personal Area Network (បណ្តាញតំបន់ផ្ទាល់ខ្លួនឥតខ្សែ) 23
ម៉ូឌឹម 23
ផាំង់ 23
Network-Interface Controller (ឧបករណ៍បញ្ជាអន្តរបណ្តាញ) 24
Wireless Local-Area Network adapter (អាដាប់ទ័របណ្តាញក្នុងតំបន់ឥតខ្សែ) 24
អាដាប់ទ័របណ្តាញតំបន់ធំទូលាយឥតខ្សែ 24
ប៊ីធ្លូស 24
Near-Field Communication (ទំនាក់ទំនងទីជិត) 24

ជំពូក 3: ការប្រើប្រាស់កុំព្យូទ័ររបស់អ្នក 25
ការសាកថ្ម 25
ប្រើប្រាស់ក្តារចុចរបស់អ្នក 25
ផ្លូវកាត់ក្តារចុច 25
ផ្លូវកាត់ក្តារចុចសម្រាប់ Windows 8.1 និង Windows RT 26
ប្តូរក្តារចុចរបស់អ្នកតាមបំណង 27
ប្រើក្តារចុចលេខនៅលើកុំព្យូទ័រយួរដៃ 28
ការប្រើប្រាស់បន្ទះប៉ះរបស់អ្នក 28
កាយវិការលើបន្ទះប៉ះ 28
ការប្រើអក្រង់ប៉ះរបស់អ្នក 29
ការប៉ះលើអក្រង់ប៉ះ 30
ការប្រើប៊ីធ្លូស 32
ការភ្ជាប់ឧបករណ៍ប៊ីធ្លូសជាមួយកុំព្យូទ័រ ឬថេប្លេតរបស់អ្នក 32
ការប្រើវិបខេម 32

ជំពូក 4: រន្ធ និងឧបករណ៍ភ្ជាប់ 34
អូឌីយ៉ូ 34
ប្រភេទនៃរន្ធអូឌីយ៉ូ 34
USB 35
រន្ធ USB 35
ស្តង់ដារ USB 35
eSATA 36

Visual Graphics Array (អារេក្រាហ្វិចមើលឃើញ)....36
Digital Visual Interface (ចំណុចប្រទាក់ឌីជីថលរូបភាព)....36
DisplayPort....36
HDMI....37
SPDIF....37

ជំពូក 5: ស្ទូហ្គ័រ និងកម្មវិធី....38
Absolute....38
Dell SupportAssist....38
ពិនិត្យកំព្យូទ័រ....38
Quickset....39
កម្មវិធី NVIDIA 3D....39

ជំពូក 6: ការស្តារប្រព័ន្ធនិងលក្ខណៈពិសេសការពារសម្រាប់អ្នកប្រើ....41
ជម្រើសស្តារប្រព័ន្ធឡើងវិញ....41
ការបម្រុងទុក និងការសង្គ្រោះឯកសាររបស់ Dell....41
ការបម្រុងទុក និងការសង្គ្រោះឯកសាររបស់ Dell មូលដ្ឋាន....42
Dell Backup and Recovery premium....42
ការស្តារឡើងវិញនូវរូបភាពដែលមានស្រាប់ពីឆាងចក្រ Dell....43
System Restore (ស្តារប្រព័ន្ធឡើងវិញ)....44
Windows 10....44
Windows 8.1....45
Windows 7....45
ឌីសប្រព័ន្ធប្រតិបត្តិការ....45
មេឌៀដំឡើងប្រព័ន្ធឡើងវិញ....46

ជំពូក 7: ការដោះស្រាយបញ្ហា....47
ជំហានដោះស្រាយបញ្ហាមូលដ្ឋាន....47
ការវិនិច្ឆ័យ....47
ការវាយតម្លៃប្រព័ន្ធមុនចូត....47
PSA ដែលបានធ្វើឱ្យប្រសើរ....47
LCD BIST....48
កូដសំឡេង....49

ជំពូក 8: BIOS....50
ការប្តូរការកំណត់ BIOS....50
ការចូលក្នុងកម្មវិធីរៀបចំ BIOS....50
កំណត់ពាក្យសម្ងាត់ BIOS ឡើងវិញ....50
លុបពាក្យសម្ងាត់....51

ជំពូក 9: ការទទួលបានជំនួយ និងទំនាក់ទំនងក្រុមហ៊ុន Dell....52

ជំពូក 10: ឃោង....53
តំបែរទាំកុំព្យូទ័រ....53
ការគ្រប់គ្រងថាមពល....53
កំណត់រចនាសម្ព័ន្ធក្នុងការកំណត់ថាមពល....53
ការកំណត់រចនាសម្ព័ន្ធឥរិយាបថចូលក្នុងថាមពល....54
Dell Power Manager (កម្មវិធីគ្រប់គ្រងថាមពល Dell)....54
ការធ្វើឱ្យអាយុកាលថ្មកាន់តែប្រសើរ....54

គន្លឹះនៃការបញ្ចូនឯកសារពីកុំព្យូទ័រផ្សេង 55
សេចក្តីណែនាំជីវបច្ចេកវិទ្យា 56
Dell និងបរិស្ថាន 57
គោលការណ៍អនុវត្តន៍តាមបទបញ្ញត្តិ 57

1

ការដំឡើងម៉ាស៊ីនកុំព្យូទ័ររបស់អ្នក

វិធីក្នុងការដំឡើងមានភាពខុសគ្នាអាស្រ័យលើកុំព្យូទ័ររបស់អ្នក។ ចំពោះការណែនាំដំឡើងជាក់លាក់សម្រាប់កុំព្យូទ័រ ឬឧបករណ៍របស់អ្នក សូមមើល *Quick Start Guide (ការណែនាំចាប់ផ្តើមរហ័ស)* ដែលបានភ្ជាប់មកជាមួយកុំព្យូទ័ររបស់អ្នក ឬមើល *Setup and Specifications (ការដំឡើង និងលក្ខណៈបច្ចេកទេស* តាមរយៈ: www.dell.com/support ។

ការភ្ជាប់អ៊ីនធឺណេត

អ្នកអាចភ្ជាប់កុំព្យូទ័ររបស់អ្នកទៅអ៊ីនធឺណេតដោយប្រើខ្សែ DSL, dial up ឬការភ្ជាប់ WWAN ។ អ្នកក៏អាចដំឡើងម៉ាតទ័រដែលមានខ្សែ ឬឥតខ្សែដើម្បីចែករំលែកការភ្ជាប់អ៊ីនធឺណេតតាមខ្សែ ឬអ៊ិនធឺណេតតាម DSL របស់អ្នកជាមួយឧបករណ៍ជាច្រើន។ ខ្សែ និងម៉ូឌឹម DSL មួយចំនួនក៏មានភ្ជាប់ឧបករណ៍តាមខ្សែផងដែរ។

ចំណាំ: មុនពេលភ្ជាប់កុំព្យូទ័ររបស់អ្នកទៅអ៊ិនធឺណេតដោយប្រើខ្សែ ឬម៉ូឌឹម DSL ត្រូវប្រាកដថាម៉ូឌឹមប្រើរបរ៉ែន និងម៉ាតទ័ររបស់អ្នកត្រូវបានកំណត់។ សម្រាប់ព័ត៌មានស្តីពីការដំឡើងម៉ូឌឹម និងម៉ាតទ័ររបស់អ្នក សូមទាក់ទងទៅអ្នកផ្តល់សេវាអ៊ីនធឺណេតរបស់អ្នក។

ការភ្ជាប់ទៅអ៊ីនធឺណិតដោយប្រើប្រាស់ LAN

1. ភ្ជាប់ខ្សែអ៊ីសឺរណិត ទៅម៉ូឌឹម ឬម៉ាតទ័រ និងទៅកាន់កុំព្យូទ័ររបស់អ្នក។
2. ពិនិត្យរកពន្លឺភ្លឹងនៅលើម៉ូឌឹមឬម៉ាតទ័រ និងកុំព្យូទ័ររបស់អ្នក។

   ចំណាំ: កុំព្យូទ័រខ្លះប្រហែលជាមិនមានពន្លឺភ្លឹងបញ្ជាក់សកម្មភាពឡើយ។
3. បើកម្មវិធីរុករកអ៊ីនធឺណិតរបស់អ្នកដើម្បីផ្ទៀងផ្ទាត់ការតភ្ជាប់អ៊ីនធឺណិត។

ការភ្ជាប់ទៅអ៊ីនធឺណេតដោយប្រើ WLAN

ចំណាំ: ត្រូវប្រាកដថាកុំព្យូទ័ររបស់អ្នកបានបើក WiFi ។ សម្រាប់ព័ត៌មានបន្ថែមអំពីការបើកបណ្តាញដោយឥតខ្សែនៅលើកុំព្យូទ័ររបស់អ្នក សូមមើល *Quick Start Guide (ការណែនាំចាប់ផ្តើមរហ័ស)* ដែលបានបំពាក់មកជាមួយកុំព្យូទ័ររបស់អ្នក ឬមើល *Setup and Specifications (ការដំឡើង និងលក្ខណៈបច្ចេកទេស)* តាមរយៈ: www.dell.com/support ។

Windows 10

1. ចុច ឬប៉ះរូបតំណាងឥតខ្សែនៅក្នុងម៉ឺនុយជួនដំណឹង។
2. ចុច ឬប៉ះបណ្តាញដែលអ្នកចង់ភ្ជាប់។
3. ចុច ឬប៉ះ **Connect (ភ្ជាប់)** ។

   ចំណាំ: បញ្ចូលពាក្យសម្ងាត់បណ្តាញប្រសិនបើស្នើសុំ។ អ្នកអាចបានកំណត់រចនាសម្ព័ន្ធពាក្យសម្ងាត់បណ្តាញពេលកំពុងដំឡើងម៉ាតទ័រ ឬម៉ាតទ័រអាចមានពាក្យសម្ងាត់បណ្តាញលំនាំដើម។ សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងក្រុមហ៊ុនផលិតម៉ាតទ័រ។
4. បើក ឬបិទការចែករំលែកឯកសារ (មិនចាំបាច់) ។

Windows 8.1

1. ចុច ឬប៉ះ **Settings (ការកំណត់)** នៅក្នុងរបារចំហៀង។
2. ចុច ឬប៉ះរូបតំណាងឥតខ្សែ។
3. ចុច ឬប៉ះបណ្តាញដែលអ្នកចង់ភ្ជាប់។
4. ចុច ឬប៉ះ **Connect (ភ្ជាប់)** ។

   ចំណាំ: បញ្ចូលពាក្យសម្ងាត់បណ្តាញប្រសិនបើបានស្នើសុំ។ អ្នកអាចកំណត់រចនាសម្ព័ន្ធពាក្យសម្ងាត់បណ្តាញពេលដំឡើងម៉ាតទ័រ ឬម៉ាតទ័រអាចមានពាក្យសម្ងាត់បណ្តាញតាមលំនាំដើម។ សម្រាប់ព័ត៌មានលម្អិតសូមទាក់ទងក្រុមហ៊ុនផលិតម៉ាតទ័រ។
5. បើក ឬបិទការចែករំលែកឯកសារ (ជាជម្រើស) ។

Windows 7

1. ចុច ឬប៉ះរូបតំណាងឥតខ្សែនៅក្នុងម៉ឺនុយជួនដំណឹង។
2. ចុចលើបណ្តាញដែលអ្នកចង់ភ្ជាប់។

3. សូមចុច **Connect (ភ្ជាប់)** ។

ចំណាំ: បញ្ចូលពាក្យសម្ងាត់បណ្តាញប្រសិនបើបានស្នើសុំ។ អ្នកអាចកំណត់រចនាសម្ព័ន្ធពាក្យសម្ងាត់បណ្តាញពេលដំឡើងជាតទីៈ ឬធ្វើតទីអាចមានពាក្យសម្ងាត់បណ្តាញតាមលំនាំដើម។ សម្រាប់ព័ត៌មានលម្អិតសូមទាក់ទងក្រុមហ៊ុនផលិតជាតទីៈ។

4. បើក ឬបិទការចែករំលែកឯកសារ (ជាជម្រើស) ។

ភ្ជាប់ទៅអ៊ីនធឺណិតដោយប្រើ WWAN

ការតភ្ជាប់ WWAN មិនតម្រូវឲ្យមានម៉ូដឹមឬជាតទីៈដើម្បី អនុញ្ញាតឲ្យកុំព្យូទ័រយួរដៃឬថេប្លេតរបស់អ្នកភ្ជាប់អ៊ីនធឺណេតទេ។ កាត WWAN នៅលើកុំព្យូទ័ររបស់អ្នកភ្ជាប់ដោយផ្ទាល់ទៅខ្លឹង បណ្តាញផ្តល់សេវា ដូចជាទូរស័ព្ទដៃរបស់អ្នកដែរ។

ប្រសិនបើអ្នកបានទិញថេប្លេតមានកិច្ចសន្យាសេវាកម្ម បណ្តាញ នោះអ៊ីនធឺណិតអាចបើកដំណើរការរួចហើយ។

ចំណាំ: ត្រូវប្រាកដថាកុំព្យូទ័ររបស់អ្នកបានបើក WiFi ។ សម្រាប់ព័ត៌មានបន្ថែមអំពីការបើកដំណើរការបណ្តាញឥតច្បែរនៅលើកុំព្យូទ័ររបស់អ្នក សូមមើល *Quick Start Guide (ការណែនាំចាប់ផ្តើមរហ័ស)* ដែលបានបំពាក់មកជាមួយកុំព្យូទ័ររបស់អ្នក ឬមើល *Setup and Specifications (ការដំឡើង និងលក្ខណៈបច្ចេកទេស)* តាមរយៈ: www.dell.com/support។

Windows 10

1. ចុច ឬប៉ះរូបតំណាងឥតច្បែរនៅក្នុងមុឺនុយជួនដំណឹង។
2. ចុច ឬប៉ះឈ្មោះបណ្តាញប្រើរយៈចៃដន្យរបស់អ្នក។
3. ចុច ឬប៉ះ **Connect (ភ្ជាប់)** ។
4. បើបានស្នើសុំ សូមវាយបញ្ចូលឈ្មោះ access point name (APN, ចំណុចចូលដំណើរការ) ឬលេខកូដ PIN ឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់។

Windows 8.1

1. ចុច ឬប៉ះ Settings (ការកំណត់) នៅក្នុងរបារចំហៀង។
2. ចុច ឬប៉ះរូបតំណាងឥតច្បែរនៅក្នុងមុឺនុយជួនដំណឹង។
3. ចុច ឬប៉ះបណ្តាញដែលអ្នកចង់ភ្ជាប់។
4. ចុច ឬប៉ះ **Connect (ភ្ជាប់)** ។
5. បើបានស្នើសុំ សូមវាយបញ្ចូលឈ្មោះ access point name (APN, ចំណុចចូលដំណើរការ) ឬលេខកូដ PIN ឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់។

Windows 7

1. ចុចរូបតំណាង **Start (ចាប់ផ្តើម)** រាយពាក្យ **Mobile Broadband Utility (ឧបករណ៍ប្រើរយៈចៃដន្យ)** ក្នុងប្រអប់ស្វែងរកហើយចុច Enter ។
2. នៅក្នុងវីនដូ **Mobile Broadband Utility (ឧបករណ៍ប្រើរយៈចៃដន្យ)** ចុច **Connect (ភ្ជាប់)** ។
3. បើបានស្នើសុំ សូមវាយបញ្ចូលឈ្មោះ access point name (APN, ចំណុចចូលដំណើរការ) ឬលេខកូដ PIN ឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់។

ការដំឡើងអូឌីយ៉ូ

កុំព្យូទ័រ និងថេប្លេត Dell មានឧបករណ៍បំពងសំឡេងដែលដំណើរការជាមួយអូឌីយ៉ូឆានែល 2 ។ ដើម្បីប្រើឧបករណ៍បំពងសំឡេងដែលមានភ្ជាប់ សូមចាក់មេរៀបហើយកំណត់កម្រិតសំឡេងតាមកម្រិតដែលអ្នកចង់បាន។

កុំព្យូទ័រ និងថេប្លេត Dell ក៏ដំណើរការជាមួយរន្ធអូឌីយ៉ូ 3.5 mm ដែលអាចឲ្យអ្នកភ្ជាប់ឧបករណ៍បំពងសំឡេងខាងក្រៅបាន។ ប្រសិនបើអ្នកកំពុងដំឡើងអូឌីយ៉ូឆានែល 2 សូមភ្ជាប់ឧបករណ៍បំពងសំឡេងទៅរន្ធកាសទំហំ 3.5 mm ឬរន្ធអូឌីយ៉ូ។

កុំព្យូទ័រលើតុ Dell អាចដំណើរការជាមួយអូឌីយ៉ូ 5.1 ឬ 7.1 ។ ប្រសិនបើអ្នកកំពុងដំឡើងអូឌីយ៉ូ 5.1 ឬ 7.1 នោះអ្នកត្រូវភ្ជាប់ឧបករណ៍បំពងសំឡេងទៅរន្ធឲ្យបានត្រឹមត្រូវសម្រាប់ឲ្យអូឌីយ៉ូបញ្ចេញបានល្អបំផុត។

ចំណាំ: សម្រាប់ព័ត៌មានបន្ថែមអំពីរន្ធដែលមានទៅលើកុំព្យូទ័រ ឬថេប្លេតរបស់អ្នក សូមមើល *Quick Start Guide (ការណែនាំចាប់ផ្តើមរហ័ស)* ដែលបានភ្ជាប់មកជាមួយកុំព្យូទ័ររបស់អ្នក ឬមើល *Setup and Specifications (ការដំឡើង និងលក្ខណៈបច្ចេកទេស)* តាមរយៈ: www.dell.com/support ។

ចំណាំ: ដើម្បីទទួលបានលទ្ធផលល្អបំផុត សូមដាក់ឧបករណ៍បំពងសំឡេងដូចបានបញ្ជាក់នៅក្នុងឯកសារភ្ជាប់ជាមួយឧបករណ៍បំពងសំឡេងរបស់អ្នក។

ចំណាំ: នៅលើកុំព្យូទ័រដែលមានកាតសំឡេងដាច់ពីគ្នា សូមភ្ជាប់ឧបករណ៍បំពងសំឡេងទៅឧបករណ៍ភ្ជាប់នៅលើកាត។

ការកំណត់រចនាសម្ព័ន្ធអូឌីយ៉ូ 5.1 និង 7.1

កំណត់រចនាសម្ព័ន្ធកុំព្យូទ័ររបស់អ្នកដើម្បីផ្តល់លទ្ធផលអូឌីយ៉ូពហុឆានែល។

Windows 10 និង 8.1

1. វាយពាក្យ **Audio** នៅក្នុងប្រអប់ស្វែងរក។

   ចំណាំ: នៅក្នុង Windows 10 ចុច ឬប៉ះរូបតំណាងស្វែងរកដើម្បីចូលទៅប្រអប់ស្វែងរក។ នៅក្នុង Windows 8.1, ចូលទៅកាន់ប៊ូតុងមុខងារស្វែងរកដើម្បីចូលប្រើប្រអប់ស្វែងរក។

2. ចុច ឬប៉ះ **Manage audio devices. (គ្រប់គ្រងឧបករណ៍អូឌីយ៉ូ។)**
3. នៅក្រោម **Playback (ទាក់ទាញវិញ)** ចុច ឬប៉ះ **Speakers or Headphones (ឧបាលិ៍ ឬកាស)**។
4. ចុច ឬប៉ះ **Configure (កំណត់រចនាសម្ព័ន្ធ)** ចុច ឬប៉ះ **Test (តេស្ត)**។

   អ្នកគួរឮសំឡេងពីឧបាលិ៍នីមួយៗ។

5. ចុច ឬប៉ះលើ **Next (បន្ទាប់)** ហើយធ្វើតាមការណែនាំនៅលើអេក្រង់។

Windows 7

1. ចុចរូបតំណាង **Start (ចាប់ផ្តើម)** វាយបញ្ចូល **Sound (សំឡេង)** នៅក្នុងប្រអប់ស្វែងរក និងចុច Enter ។

   នៅក្នុងបញ្ជីលទ្ធផល ចុច **Sound**។ ឬចុច **Start**#menucascade-separator**Control Panel**#menucascade-separator**Hardware and Sound**#menucascade-separator**Sound**។

2. អ៊ូសរើស **Speakers** រួចចុច **Configure**។

   ផ្ទាំង **Speaker Setup** នឹងបង្ហាញឡើង។

3. នៅក្រោម **Playback (ទាក់ទាញវិញ)** ចុច ឬប៉ះ **Speakers or Headphones (ឧបាលិ៍ ឬកាស)**។
4. អ៊ូសរើសការកំណត់រចនាសម្ព័ន្ធឧបាលិ៍នៅក្រោម **Audio channels** ។ ហើយចុច **Test**។

   អ្នកគួរឮសំឡេងពីឧបាលិ៍នីមួយៗ។

5. ចុច **Next (បន្ទាប់)** ហើយធ្វើតាមការណែនាំនៅលើអេក្រង់។

ការភ្ជាប់ឧបករណ៍បំពងសំឡេង 5.1



រូប 1. ការភ្ជាប់ឧបករណ៍បំពងសំឡេង 5.1

1. ឧបករណ៍ភ្ជាប់អូឌីយ៉ូខាងក្រោយនៅលើកុំព្យូទ័រ
2. កណ្តាល/LFE ជុំវិញក្រៅនៅលើកុំព្យូទ័រ
3. ឧបករណ៍ភ្ជាប់អូឌីយ៉ូផ្នែកខាងមុខនៅលើកុំព្យូទ័រ
4. ខ្សែអូឌីយ៉ូតាណែល 5.1
5. កណ្តាល/ LFE ជុំវិញក្រៅលើឧបករណ៍បំពងសំឡេង
6. ឧបករណ៍ភ្ជាប់អូឌីយ៉ូផ្នែកខាងមុខនៅលើឧបករណ៍បំពងសំឡេង
7. ឧបករណ៍ភ្ជាប់អូឌីយ៉ូផ្នែកខាងក្រោយនៅលើឧបករណ៍បំពងសំឡេង

ការតភ្ជាប់ឧបករណ៍បំពងសំឡេង 7.1



រូប 2. ការតភ្ជាប់ឧបករណ៍បំពងសំឡេង 7.1

1. ឧបករណ៍តភ្ជាប់អូឌីយ៉ូខាងក្រោយនៅលើកុំព្យូទ័រ
2. ជុំវិញក្រៅកណ្តាល/LFE នៅលើកុំព្យូទ័រ
3. ឧបករណ៍តភ្ជាប់អូឌីយ៉ូចំហៀងនៅលើកុំព្យូទ័រ
4. ឧបករណ៍តភ្ជាប់អូឌីយ៉ូខាងមុខនៅលើកុំព្យូទ័រ
5. ខ្សែអូឌីយ៉ូអាណាឡុង 7.1
6. ជុំវិញក្រៅកណ្តាល/LFE នៅលើឧបករណ៍បំពងសំឡេង
7. ឧបករណ៍តភ្ជាប់អូឌីយ៉ូខាងមុខនៅលើឧបករណ៍បំពងសំឡេង
8. ឧបករណ៍តភ្ជាប់អូឌីយ៉ូខាងក្រោយនៅលើឧបករណ៍បំពងសំឡេង
9. ឧបករណ៍តភ្ជាប់អូឌីយ៉ូចំហៀងនៅលើឧបករណ៍បំពងសំឡេង

ការដំឡើងម៉ាស៊ីនព្រីនរបស់អ្នក

អ្នកអាចភ្ជាប់ម៉ាស៊ីនព្រីនតាមរន្ធ USB នៅលើកុំព្យូទ័ររបស់អ្នក។ ម៉ាស៊ីនព្រីនខ្លះក៏អាចភ្ជាប់បណ្តាញ Wi-Fi និងប៊្លូធូសបានផងដែរ។

ចំណាំ: លក្ខណៈពិសេសនៃម៉ាស៊ីនព្រីន និងដំហានក្នុងការដំឡើងអាចខុសគ្នាអាស្រ័យលើម៉ូដែលម៉ាស៊ីនព្រីន។ ចំពោះព័ត៌មានបន្ថែមអំពីការដំឡើងម៉ាស៊ីនព្រីន សូមមើលឯកសារដែលភ្ជាប់មកជាមួយម៉ាស៊ីនព្រីនរបស់អ្នក។

- ប្រសិនបើអ្នកដំឡើងម៉ាស៊ីនព្រីនដោយប្រើខ្សែ សូមភ្ជាប់ម៉ាស៊ីនព្រីនទៅកុំព្យូទ័ររបស់អ្នកដោយប្រើខ្សែ USB មុនពេលអនុវត្តជំហានទាំងនេះ។
- ប្រសិនបើអ្នកដំឡើងម៉ាស៊ីនព្រីនឥតខ្សែសូមធ្វើតាមការណែនាំនៅក្នុងឯកសារនៃម៉ាស៊ីនព្រីនរបស់អ្នក។

Windows 10 និង 8.1

1. វាយពាក្យ **Devices** នៅក្នុងប្រអប់ស្វែងរក។

   ចំណាំ: នៅក្នុង Windows 10 ចុច ឬប៉ះរូបតំណាងស្វែងរកដើម្បីចូលទៅប្រអប់ស្វែងរក។ នៅក្នុង Windows 8.1, ចូលទៅកាន់ថ្ងៃតុងមុខងារស្វែងរកដើម្បីចូលប្រើប្រអប់ស្វែងរក។
2. ចុច ឬប៉ះ **Devices and Printers**។
3. ចុច ឬប៉ះ **Add a printer**។

   ផ្ទាំង **Add a device** បង្ហាញឡើង។
4. អនុវត្តតាមការណែនាំនៅលើអេក្រង់។

   ចំណាំ: ប្រសិនបើព្រីនធ័ររបស់អ្នកត្រូវបានដំឡើង វាគួរតែលេចឡើងក្នុងបញ្ជីនៅផ្នែកខាងស្តាំ។ ប្រសិនបើព្រីនធ័ររបស់អ្នកមិនស្ថិតនៅក្នុងបញ្ជីនេះទេ សូមចុច ឬប៉ះ **Add a device** នៅផ្នែកខាងលើនៃឧបករណ៍។ អ្នកនឹងត្រូវជ្រើសរើសព្រីនធ័ររបស់អ្នកពីបញ្ជីដើម្បីដំឡើងវា។ សម្រាប់ព័ត៌មានបន្ថែមស្តីពីការដំឡើងព្រីនធ័រ សូមមើលឯកសារដែលបានភ្ជាប់មកជាមួយព្រីនធ័ររបស់អ្នក។

Windows 7

1. ចុច **Start**#menucascade-separator**ឧបករណ៍ និងព្រិនធ័រ**។
2. ចុច **បន្ថែមព្រិនធ័រ**។

   ផ្ទាំង **បន្ថែមព្រិនធ័រ** នឹងបង្ហាញឡើង។

3. ធ្វើតាមការណែនាំនៅលើអេក្រង់។

   ចំណាំ: អ្នកអាចស្នើសុំឲ្យដំឡើងក្រាយវ៉ឺព្រិនធ័ររបស់អ្នកខណៈពេលបន្ថែមព្រិនធ័រ។ ប្រើមេឡៀក្រាយវ៉ឺព្រិនធ័រ ឬទាញយកកម្មវិធីពីគេហទំព័ររបស់ក្រុមហ៊ុនផលិតម៉ាស៊ីនព្រិនធ័រ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីការដំឡើងព្រិនធ័រ សូមមើលឯកសារដែលបានភ្ជាប់មកជាមួយព្រិនធ័ររបស់អ្នក។

ការដំឡើងវិបខេម

វិបខេមបញ្ចូលគ្នា

វិបខេមបញ្ចូលគ្នា មាននៅលើអេក្រង់កុំព្យូទ័រយួរដៃ ឬអេក្រង់ខាងក្រៅ។ បើសិនជាអ្នកបញ្ជាទិញវិបខេមជាមួយកុំព្យូទ័ររបស់អ្នក នោះគ្រាយវ៉ែ និងសូហ្វវ៉ែរត្រូវបានដំឡើង នៅពេលដែលអ្នកទទួលបានកុំព្យូទ័ររបស់អ្នក។ ប្រើប្រាស់មេឡៀដែលភ្ជាប់ជាមួយកុំព្យូទ័រតប៉ុណ្ណោះដើម្បីដំឡើងវាឡើងវិញ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល Using the webcam (ការប្រើប្រាស់វិបខេម)។

វិបខេមខាងក្រៅ

ប្រើប្រាស់មេឡៀដែលត្រូវបានភ្ជាប់មកជាមួយវិបខេមរបស់អ្នក ដើម្បីដំឡើងគ្រាយវ៉ែ និងសូហ្វវ៉ែរដែលចាំបាច់ផ្សេងទៀត ដើម្បីប្រើប្រាស់លក្ខណៈពិសេសទាំងអស់នៃវិបខេមរបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមមើលឯកសារដែលមានភ្ជាប់ជាមួយវិបខេមរបស់អ្នក។

ការដំឡើងប៊្លូធូស

អ្នកអាចបើកប៊្លូធូសនៅលើកុំព្យូទ័ររបស់អ្នកដោយបើកបណ្តាញឥតខ្សែ។ កុំព្យូទ័រនិងថេប្លេតតាមត្រូវបានភ្ជាប់មកជាមួយកាតប៊្លូធូសដែលមានស្រាប់។ សម្រាប់ព័ត៌មានបន្ថែមអំពីការភ្ជាប់ឧបករណ៍របស់អ្នកជាមួយកុំព្យូទ័ររបស់អ្នកសូមមើល Using Bluetooth (ការប្រើប៊្លូធូស) ។

ចំណាំ: ដើម្បីរកឱ្យឃើញថាកុំព្យូទ័រ ឬថេប្លេតរបស់អ្នកមាន កាតប៊្លូធូសខាងក្នុងឬអត់ សូមមើល *Quick Start Guide (ការណែនាំចាប់ផ្តើមរហ័ស)* ដែលបានភ្ជាប់មកជាមួយកុំព្យូទ័ររបស់អ្នក ឬមើល *Setup and Specifications (ការតំឡើង និងលក្ខណៈបច្ចេកទេស)* តាមរយៈ: www.dell.com/support ។

ការភ្ជាប់ម៉ូនីទ័រច្រើន

ក្រាហ្វិច ឬកាតវីដេអូកុំព្យូទ័រលើតុ ភាគច្រើនអាចដំណើរការជាមួយម៉ូនីទ័រពីរ ឬច្រើនអាស្រ័យលើកាតក្រាហ្វិក និងលក្ខណៈបច្ចេកទេសរបស់កុំព្យូទ័រ។ ជាទូទៅកុំព្យូទ័រយួរដៃអាចដំណើរការបានតែម៉ូនីទ័រពីរប្រើរួមអាស្រ័យលើលក្ខណៈបច្ចេកទេសរបស់កុំព្យូទ័រ។ កំណត់ប្រភេទនៃឧបករណ៍ភ្ជាប់វីដេអូដែលមាននៅលើកុំព្យូទ័រ ឬកុំព្យូទ័រយួរដៃរបស់អ្នក។ ចំនួនឧបករណ៍ភ្ជាប់វីដេអូអាស្រ័យលើប្រភេទកាតក្រាហ្វិច ដែលត្រូវបានដំឡើងនៅក្នុងកុំព្យូទ័រ ឬកុំព្យូទ័រយួរដៃ។

1. ភ្ជាប់ខ្សែថាមពលទៅម៉ូនីទ័រ និងព្រឹត្តិ្ត។
2. ភ្ជាប់ខ្សែវីដេអូពីម៉ូនីទ័រទៅឧបករណ៍ភ្ជាប់វីដេអូនៅលើកុំព្យូទ័រ ឬកុំព្យូទ័រយួរដៃរបស់អ្នក។
3. ចុចបើកម៉ូនីទ័រ និងកុំព្យូទ័រ ឬកុំព្យូទ័រយួរដៃរបស់អ្នក។

Windows 10

នៅពេលដែលខ្សែត្រូវបានភ្ជាប់ដោយសុវត្ថិភាព កុំព្យូទ័ររបស់អ្នកនឹងរកឃើញដោយស្វ័យប្រវត្តិ ព្រមទាំងបង្ហាញអេក្រង់ កុំព្យូទ័រលើម៉ូនីទ័រដែលបានភ្ជាប់។ ឥឡូវអ្នកអាចជ្រើសរើសរបៀបបង្ហាញដែលសាកសមនឹងតម្រូវការរបស់អ្នក។

Microsoft Windows ផ្តល់ជម្រើសរបៀបបង្ហាញច្រើនពីវិធីដែលអេក្រង់កុំព្យូទ័រត្រូវបានបង្ហាញនៅលើម៉ូនីទ័រជាច្រើនដែលភ្ជាប់ទៅកុំព្យូទ័ររបស់អ្នក។

- **អេក្រង់កុំព្យូទ័រតែប៉ុណ្ណោះ** - ប្រើតែអេក្រង់ទី 1 ហើយគ្មានបង្ហាញអ្វីនៅលើអេក្រង់ទី 2 ។ ម៉ូនីទ័រទីពីរត្រូវបានអើពើ ហើយមានតែម៉ូនីទ័របឋមប៉ុណ្ណោះដែលត្រូវបានប្រើ។
- **ស្ទួន** (ក៏ត្រូវបានចាម៉ូតកូន) - បង្ហាញរូបភាពកុំព្យូទ័រ ទាំងមូលនៅលើអេក្រង់ទាំងពីរ។ ម៉ូនីទ័រទីពីរ ឬផ្សេងទៀតនឹងមានបញ្ហាចំពោះម៉ូនីទ័របឋម។
- **ពង្រីក** - ពង្វាងរូបភាពមុខនៅលើអេក្រង់ពីរ។ អេក្រង់រូបភាពមុខនៃកុំព្យូទ័រលើតុរបស់អ្នកត្រូវបានពង្រីកគ្រប់ម៉ូនីទ័រដែលបានរកឃើញ និងអនុញ្ញាតឱ្យអ្នកមានអេក្រង់ កុំព្យូទ័រលើតុ ដែលគ្របដណ្តប់គ្រប់ម៉ូនីទ័រទាំងអស់។
- **អេក្រង់ទីពីរតែប៉ុណ្ណោះ** - ប្រើតែអេក្រង់ទី 2 ហើយ មិន បង្ហាញអ្វីនៅលើអេក្រង់ទី 1 ។ ម៉ូនីទ័របឋមនឹងត្រូវបានបិទ ហើយមានតែម៉ូនីទ័រទីពីរប៉ុណ្ណោះដែលនឹងត្រូវបានប្រើ។

Windows 8

ម៉ឺនុ Windows

1. ហៅ **Windows Charms** ដោយអូសពីខាងស្តាំ ឬរំកិលម៉ៅទៅជ្រុងខាងស្តាំដៃ។
2. ជ្រើសរើស **Devices (ឧបករណ៍)**។
3. ជ្រើសរើស **អេក្រង់ទីពីរ** ។
4. សូមជ្រើសយកជម្រើសណាមួយដូចខាងក្រោម៖
   - **អេក្រង់កុំព្យូទ័រតែប៉ុណ្ណោះ** - ប្រើតែអេក្រង់ទី 1 ហើយគ្មានបង្ហាញអ្វីនៅលើអេក្រង់ទី 2 ។ ម៉ូនីទ័រទីពីរត្រូវបានអើរើ ហើយមានតែម៉ូនីទ័របឋមប៉ុណ្ណោះដែលត្រូវបានប្រើ។
   - **ស្ទួន** (ក៏ត្រូវបានចាម៉ូតក្លូន) - បង្ហាញផ្ទៃកំព្យូទ័រ ទាំងមូលនៅលើអេក្រង់ទាំងពីរ។ ម៉ូនីទ័រទីពីរ ឬផ្សេងទៀតនឹងបញ្ចាំងម៉ូនីទ័របឋម។
   - **ពង្រីក** - ពន្លាតរឹទ្ធខាងមុខនៅលើអេក្រង់ពីរ។ អេក្រង់រឹទ្ធខាងមុខនៃកុំព្យូទ័រលើតុរបស់អ្នកត្រូវបានពង្រីកគ្រប់ម៉ូនីទ័រដែលបានរកឃើញ និងអនុញ្ញាតឱ្យអ្នកមានអេក្រង់ កុំព្យូទ័រលើតុ ដែលគ្របដណ្តប់គ្រប់ម៉ូនីទ័រទាំងអស់។
   - **អេក្រង់ទីពីរតែប៉ុណ្ណោះ** - ប្រើតែអេក្រង់ទី 2 ហើយ មិន បង្ហាញអ្វីនៅលើអេក្រង់ទី 1 ។ ម៉ូនីទ័របឋមនឹងត្រូវបានបិទ ហើយមានតែម៉ូនីទ័រទីពីរប៉ុណ្ណោះដែលនឹងត្រូវបានប្រើ។

បែបបទសម្រាប់កុំព្យូទ័រលើតុតាមប្រពៃណី

1. សូមចូលទៅ **Control Pane** ហើយជ្រើស **Display** ។
2. ជ្រើសរើស **Change Display Settings (ប្តូរការកំណត់ការបង្ហាញ)** នៅខាងឆ្វេង។
3. នៅក្នុងផ្ទាំងវិនដូ **Change Display Settings** ចុច និង អូស ម៉ូនីទ័រនិម្មិតដើម្បីធ្វើគ្រាប់តាមពីការរៀបចំផ្ទាល់របស់អ្នក។
4. ចុច **OK (យល់ព្រម)** ដើម្បីបញ្ចប់។

Windows 7

1. បិទកម្មវិធីដែលបើកទាំងអស់។
2. សង្កត់គ្រាប់ចុចប្រតិបត្តិការ Windows ឲ្យជាប់ រួចចុចគ្រាប់ចុច P នៅលើក្តារចុចរបស់អ្នក។
3. ជ្រើសរើសជម្រើសមួយក្នុងចំណោមខាងក្រោម៖
   - **Computer only (កុំព្យូទ័រតែប៉ុណ្ណោះ)**—បង្ហាញរូបភាពអេក្រង់តែនៅលើអេក្រង់កុំព្យូទ័រយូរដៃរបស់អ្នកប៉ុណ្ណោះ។
   - **Duplicate (ស្ទួន)**—ធ្វើឱ្យរូបភាពអេក្រង់កុំព្យូទ័រយូរដៃរបស់អ្នកនៅលើអេក្រង់ទាំងពីរ ដោយផ្តល់កលើអេក្រង់ដែលមានកម្រិតបង្ហាញទាប។
   - **Extend (បន្ថែម)**—ផ្ទាស់ទីផ្ទាំងពីអេក្រង់មួយទៅអេក្រង់មួយទៀត ដោយចុចលើ Title Bar (របារចំណងជើង) នៃវិនដូ និងអូសវិនដូទៅទីតាំងថ្មី។
   - **Projector only (តែឧបករណ៍បញ្ចាំងប៉ុណ្ណោះ)**—ជាទូទៅត្រូវបានជ្រើសរើសនៅពេលអ្នកប្រើកុំព្យូទ័រយូរដៃរបស់អ្នកជាកុំព្យូទ័រលើតុ ដូច្នេះអ្នកអាចរីករាយជាមួយគុណភាពបង្ហាញខ្ពស់ជាងមុននៃអេក្រង់ខាងក្រៅធំ។

2

អំពីកុំព្យូទ័ររបស់អ្នក

ផ្នែកនេះផ្តល់ជូនព័ត៌មានអំពីផ្នែកដែលមាននៅក្នុងកុំព្យូទ័ររបស់អ្នក។

អាដាប់ទ័រថាមពល

អាដាប់ទ័រថាមពលត្រូវបានប្រើដើម្បីផ្គត់ផ្គង់ថាមពលទៅកុំព្យូទ័រចល័ត ថេប្លេតនិងកុំព្យូទ័រលើតុមួយចំនួន។ ឧបករណ៍អាដាប់ទ័ររបស់ Dell មានអាដាប់ទ័រនិងខ្សែថាមពល។ អត្រាអាដាប់ទ័រថាមពល (90 W, 65 W និងច្រើនជាងនេះ) អាស្រ័យលើឧបករណ៍ដែលវាត្រូវបានរចនាឡើង ហើយខ្សែថាមពលប្រែប្រួលតាមប្រទេសដែលអាដាប់ទ័រត្រូវបានដឹកជញ្ជូន។

ប្រយ័ត្ន: ដើម្បីជៀសវាងការខូចខាតកុំព្យូទ័ររបស់អ្នក វាត្រូវបានណែនាំឲ្យប្រើតែអាដាប់ទ័រដែលត្រូវបានដឹកជញ្ជូនជាមួយនឹងឧបករណ៍ របស់អ្នក ឬអាដាប់ទ័រថាមពលដែលត្រូវបានអនុម័តដោយ ក្រុមហ៊ុន Dell ។

ថ្ម

ថ្មត្រូវបានចាត់ថ្នាក់ដោយការផ្តល់ចំណាត់ថ្នាក់ថាមពលរបស់ពួកវាដូចជា 45 WHr, 65 WHr ជាដើម។ ថ្មនេះអនុញ្ញាតឲ្យអ្នកប្រើឧបករណ៍របស់អ្នកនៅពេលវាមិនត្រូវបានភ្ជាប់ទៅព្រីមើង។ វដ្តជីវិតនៃថ្មគឺចំនួនដងដែលវាអាចត្រូវបានផ្តាច់ និងបញ្ចូលថ្មដោយមិនប៉ះពាល់ដល់ពេលវេលាប្រតិបត្តិការនោះទេ។ បន្ទាប់ពីរយៈកាលថ្មដល់ដំណាក់កាលកំណត់នៃជីវិតរបស់វា អ្នកត្រូវតែប្តូរថ្ម។ អាស្រ័យលើម៉ូដែលកុំព្យូទ័រ ថ្មនៅលើកុំព្យូទ័ររបស់អ្នកអាចត្រូវបានប្តូរ ឬដោយអ្នកប្រើ ឬប្រើបាលជាតម្រូវឲ្យអ្នកបច្ចេកទេសសេវាកម្មរបស់ Dell ប្តូរជូន។

ចំណាំ: ថ្មដែលមានសមត្ថភាពខ្ពស់ជាទូទៅមានវដ្តជីវិតយូរជាងមុនព្រោះអ្នកត្រូវការសាកថ្មដែលមានសមត្ថភាពខ្ពស់តិចជាងបើប្រៀបធៀបទៅនឹងថ្មដែលមានថាមពលទាប។

ចំណាំ: សម្រាប់ព័ត៌មានជំនួយអំពីការបង្កើនអាយុកាល សូមមើល Improving battery life (ការបង្កើនអាយុកាលថ្ម)។

ចំណាំ: លក្ខណៈពិសេស Dell Power Manager មិនត្រូវបានគាំទ្រនៅក្នុងប្រព័ន្ធ Alienware ឡើយ។

ថ្មគ្រាប់សំប៉ែត

ថ្មគ្រាប់សំប៉ែតផ្តល់ថាមពលទៅ Complementary Metal-Oxide Semiconductor (CMOS) នៅពេលដែលកុំព្យូទ័រត្រូវបានបិទ។ បន្ទះឈីប CMOS មានពេលវេលា កាលបរិច្ឆេទ និងព័ត៌មានកំណត់រចនាសម្ព័ន្ធផ្សេងទៀតអំពីកុំព្យូទ័ររបស់អ្នក។ ក្រោមលក្ខខណ្ឌប្រើប្រាស់ធម្មតាថ្មគ្រាប់ សំប៉ែតអាចមានអាយុកាលជាច្រើនឆ្នាំ។ កត្តាដែលប៉ះពាល់ដល់អាយុកាលថ្មគ្រាប់ សំប៉ែតមានដូចជាប្រភេទនៃឧបករណ៍ប្រព័ន្ធ សីតុណ្ហភាព ពេលវេលាដែលកុំព្យូទ័រត្រូវបានបិទ ។ល។

បន្ទះប៉ះ

បន្ទះប៉ះមាននៅលើកុំព្យូទ័រយួរដៃស្ទើរតែទាំងអស់ និងផ្តល់មុខងាររបស់ម៉ៅ។ វាមានផ្ទៃផ្តេផ្តាសតបនិងការប៉ះ ដែលនឹងពិចលនា និងទីតាំងនៃម្រាមដៃរបស់អ្នក។ អ្នកអាចប្រើប្រាស់បន្ទះប៉ះដើម្បីផ្លាស់ទីម៉ៅ អូស ឬផ្លាស់ទីធាតុដែលបានជ្រើសរើស និងចុចដោយធ្វើការចុចឈើរឹង។ បន្ទះប៉ះដែលមានកាយវិការ គាំទ្រកាយវិការដូចជាពង្រីក ឡើង បង្វិល រមូរ និងផ្សេងៗទៀត។ អ្នកក៏អាចទិញបន្ទះប៉ះខាងក្រៅផងដែរ។ បន្ទះប៉ះច្បាស់លាស់ គឺជាឧបករណ៍បញ្ចូលកម្រិតថ្មី ដែលផ្តល់ការបញ្ចូលការចង្អុលនិងមុខងារកាយវិការដែលមានភាពច្បាស់លាស់ខ្ពស់។ បន្ទះប៉ះច្បាស់លាស់ធ្វើយផ្តងជាមួយប្រព័ន្ធប្រតិបត្តិការងាយថ្នាល់ដោយមិនត្រូវការជ្រាយអីឡើយ។

ចំណាំ: សម្រាប់ព័ត៌មានបន្ថែម សូមមើល Using your touchpad (ការប្រើប្រាស់បន្ទះប៉ះរបស់អ្នក)។

អេក្រង់

អេក្រង់ត្រូវបានចាត់ថ្នាក់យោងទៅតាមទំហំអេក្រង់ គុណភាពបង្ហាញ គុណភាពពណ៌ ជាដើម។ ជាទូទៅអេក្រង់ដែលមានគុណភាពបង្ហាញខ្ពស់ និងការគាំទ្រ ពណ៌ល្អប្រសើរផ្តល់នូវគុណភាពរូបភាពកាន់តែប្រសើរឡើង។ អេក្រង់ខាងក្រៅមួយចំនួនក៏មានរន្ធ USB, ឧបករណ៍រាន់ភាតមមៀ ជាដើម។ អេក្រង់អាចគាំទ្រលក្ខណៈពិសេសដូចជាអេក្រង់ប៉ះ, 3D, និងការភ្ជាប់ឥតខ្សែ។

អេក្រង់ប៉ះ

អេក្រង់ប៉ះគឺជាឧបករណ៍បង្ហាញដែលអនុញ្ញាតឲ្យអ្នកធ្វើអន្តរកម្មជាមួយវត្ថុនៅលើអេក្រង់ដោយប៉ះអេក្រង់ដំនួសឲ្យការប្រើម៉ៅ បន្ទះប៉ះ ឬក្តារចុច។ អ្នកអាចដំណើរការអេក្រង់ប៉ះជាមួយម្រាមដៃ ឬវត្ថុអសកម្មផ្សេងទៀតដូចជាប៊ិចជាដើម។ អេក្រង់ប៉ះត្រូវបានគេប្រើជាទូទៅនៅក្នុងទូរស័ព្ទ ថេប្លេត និងច្នៃនទៀត។ បច្ចេកវិទ្យាអេក្រង់ប៉ះត្រូវបានគេប្រើជាទូទៅគឺការប៉ះដោយប្រើក្រយ៉ាំដៃ និងមិនប្រើក្រយ៉ាំដៃ។

ចំណាំ: អេក្រង់ប៉ះអាចមិនត្រូវបានគាំទ្រនៅលើកុំព្យូទ័រទាំងអស់។

ចំណាំ: សម្រាប់ព័ត៌មានបន្ថែមសូមមើល ប្រើអេក្រង់ប៉ះរបស់អ្នក ។

3D

អេក្រង់សមត្ថភាព 3D អាចបង្ហាញរូបភាព និងវីដេអូ 3D ។ 3D ដំណើរការដោយបង្ហាញរូបភាព 2D ងាច់ដោយម៉ែកទៅម្ខែកខាងឆ្វេង និងខាងស្តាំ។ រូបភាពទាំងនេះត្រូវបានបញ្ចូលគ្នា និងបកស្រាយដោយខួរក្បាលថាជារូបភាពតែមួយ។

ចំណាំ: អ្នកអាចត្រូវការវ៉ែនតា 3D ពិសេសដើម្បីមើលរូបភាព 3D ។

ការបង្ហាញឥតខ្សែ

លក្ខណៈពិសេសនៃការបង្ហាញឥតខ្សែ អនុញ្ញាតឲ្យអ្នកចែករំលែកអេក្រង់កុំព្យូទ័ររបស់អ្នកជាមួយទូរទស្សន៍ដែលត្រូវគ្នា ដោយមិនចាប់ប្រើខ្សែ។ ដើម្បីពិនិត្យថាតើទូរទស្សន៍របស់អ្នកគាំទ្រលក្ខណៈពិសេសនេះឬក៏អត់ សូមមើលឯកសាររបស់ទូរទស្សន៍។

ចំណាំ: ការបង្ហាញឥតខ្សែអាចមិនត្រូវបានគាំទ្រនៅលើកុំព្យូទ័រទាំងអស់ឡើយ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល www.intel.com ។

កាមេរ៉ា

វិបខេម

វិបខេមអនុញ្ញាតឲ្យអ្នកជជែកកំសាន្តជាវីដេអូ ថតរូបភាព និងថតវីដេអូបាន។

កាមេរ៉ា 3D

អ្នកអាចប្រើកាមេរ៉ា 3D ដើម្បីថត និងស្ទ្រីមវីដេអូ 3 វិមាត្រដែលធ្វើឲ្យវាអាចមើលឃើញចម្ងាយ ចំហាំនៃវត្ថុតាមរយៈឧបករណ៍អត្ថញ្ញាណដែលភ្ជាប់មកជាមួយ។ លក្ខណៈពិសេសនេះអនុញ្ញាតឲ្យមានអត្ថកម្មកាន់តែប្រសើរឡើងក្នុងអំឡុងពេលឱយាយវីដេអូ ការលេងហ្គេមតាមអ៊ីនធឺណិតជាដើម។

កាមេរ៉ា Intel RealSense 3D

កាមេរ៉ា RealSense ចំពាក់កព្ឆាក់កាមេរ៉ាពីដែល កាមេរ៉ា 2D ស្តង់ដារសម្រាប់រូបថត និងវីដេអូធម្មតារួមជាមួយកាមេរ៉ាអ៊ីនហ្វ្រារ៉េដ និងម៉ាស៊ីនបញ្ចាំងឡាស៊ែរអ៊ីនហ្វ្រារ៉េដ។ ផ្នែកអ៊ីនហ្វ្រារ៉េដអនុញ្ញាតឲ្យ RealSense មើលឃើញចម្ងាយរវាងវត្ថុ ការរ៉ែងចែកវត្ថុពីស្រទាប់ផ្ទៃ នៅពីក្រោយ និងអនុញ្ញាតឲ្យមានការទទួលស្គាល់ពីវត្ថុ ផ្ទៃមុខ និងកាយវិការល្អជាងកាមេរ៉ាធម្មតា។ ឧបករណ៍នេះមានបីជម្រើស៖ ខាងមុខ ខាងក្រោយ និងថតរូប។

អេក្រង់ឥតខ្សែ

លក្ខណៈពិសេសនៃអេក្រង់ឥតខ្សែអនុញ្ញាតឱ្យអ្នកចែករំលែកការបង្ហាញកុំព្យូទ័រជាមួយទូទស្សន៍ដោយមិនចាំបាច់ប្រើខ្សែ។ ដើម្បីពិនិត្យមើលថាតើទូទស្សន៍របស់អ្នកដំណើរការជាមួយ លក្ខណៈពិសេសនេះឬអត់ សូមមើលឯកសារស្តីពីទូទស្សន៍។

ចំណាំ: ការបង្ហាញឥតខ្សែអាចមិនដំណើរការនៅលើកុំព្យូទ័រទាំងអស់បានទេ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល www.intel.com ។

ក្តារចុច (ឃីបត)

ក្តារចុចអនុញ្ញាតឱ្យអ្នកវាយអក្សរ និងអនុវត្តមុខងារពិសេសដោយប្រើគ្រាប់ចុចផ្នែកកាត់។ ចំនួនគ្រាប់ក្តារចុច និងតួអក្សរអាចខុសគ្នានៅលើក្តារចុចដោយផ្អែកលើប្រទេសដែលក្តារចុចត្រូវបានជញ្ជូនទៅ។ កុំព្យូទ័រយួរដៃមានភ្ជាប់ក្តារចុចរួចជាស្រេច។ ថេប្លេតជាទូទៅមានក្តារចុចលើអេក្រង់ហើយថេប្លេតខ្លះក៏អាចប្រើក្តារចុចខាងក្រៅផងដែរ។ កុំព្យូទ័រលើតុ Dell មានក្តារចុចខាងក្រៅភ្ជាប់ដោយប្រើ USB ឬឥតខ្សែ។

គ្រាប់ចុចទូទៅដែលមាននៅលើក្តារចុចគឺ៖

- គ្រាប់ចុចលេខនិងអក្សរ សម្រាប់វាយអក្សរ លេខ វណ្ណយុត្ត និងនិមិត្តសញ្ញាផ្សេងៗ
- គ្រាប់ចុចផ្នែកាត់ ពហុមេឌៀ និងកម្មវិធី
- គ្រាប់ចុចបញ្ជាដូចជា Ctrl, Alt, Esc និង Windows
- គ្រាប់ចុចផ្នែកាត់ប្រើដើម្បីអនុវត្តមុខងារជាក់លាក់ ឬដើម្បីដំណើរការលក្ខណៈពិសេសជាក់លាក់ណាមួយ
- គ្រាប់ចុចមុខងារ F1 រហូតដល់ F1
- គ្រាប់ចុចយុករកសម្រាប់ផ្លាស់ទីទស្សន៍ទ្រនិចនៅក្នុងឯកសារ ឬវីនដូ

ក្តារចុចខាងក្រៅ

ក្តារចុចខាងក្រៅត្រូវបានប្រើជាមួយកុំព្យូទ័រយួរដៃ និងកុំព្យូទ័រលើតុ។ កុំព្យូទ័រយួរដៃជាទូទៅមានក្តារចុចដែលមានស្រាប់។ ក្តារចុចខាងក្រៅត្រូវបានប្រើជាទូទៅជាមួយកុំព្យូទ័រលើតុ។ ក្តារចុចខ្លះអាចមានលក្ខណៈពិសេសដូចជាគ្រាប់ចុចសម្រាប់ការសាមីកច្រិតសំឡេង ផ្នែកាត់កម្មវិធី បន្ទះប៉ះដែលមានស្រាប់ គ្រាប់ចុចផ្នែកាត់កម្មវិធី ពន្លឺខាងក្រោយជាដើម។

ពន្លឺក្រោយក្តារចុច

ពន្លឺខាងក្រោយមាននៅលើក្តារចុចមួយចំនួនបង្ហាញពីឥទ្ធិពលសញ្ញាលើគ្រាប់ចុចសម្រាប់ប្រើក្តារចុចក្នុងបរិយាកាសងងឹត។ អ្នកអាចបើកពន្លឺខាងក្រោយដោយដៃ ឬកំណត់រចនាសម្ព័ន្ធពន្លឺភ្លឺឱ្យបើកដោយស្វ័យប្រវត្តិនៅពេលកុំព្យូទ័ររបស់អ្នកត្រូវបានដាក់នៅក្នុងបរិយាកាសងងឹត។

ពន្លឺខាងក្រោយក្តារចុចនៅលើកុំព្យូទ័រយួរដៃ Dell មានម្លឹងបំភ្លឺខុសៗគ្នា។ ចុច Fn និងគ្រាប់ចុចព្រួញខាងស្តាំដើម្បីប្តូរវាងស្ថានភាពម្លឹងបំភ្លឺផ្សេងៗ។ ពន្លឺខាងក្រោយក្តារចុច RGB ត្រូវបានបំភ្លឺដោយពន្លឺ RGB ក្នុងមួយគ្រាប់ចុចនៅលើក្តារចុច។ អ្នកអាចកំណត់ការកំណត់នៃពន្លឺខាងក្រោយឱ្យសមនឹងសក្ដានុពលនៅក្នុងការលេងហ្គេមរបស់អ្នក។

ចំណាំ: ពន្លឺខាងក្រោយក្តារចុចអាចមិនមាននៅលើកុំព្យូទ័រទាំងអស់ទេ។ ដើម្បីពិនិត្យដឹងថាពន្លឺខាងក្រោយក្តារចុចនៅលើកុំព្យូទ័ររបស់អ្នកមានឬអត់ សូមមើល *Quick Start Guide (ការណែនាំចាប់ផ្តើមរហ័ស) ដែលបានភ្ជាប់ជាមួយកុំព្យូទ័ររបស់អ្នក* ឬមើល *Setup and Specifications (ការដំឡើង និងលក្ខណៈបច្ចេកទេស)* តាមរយៈ www.dell.com/support។

ក្តារចុចលើអក្រង់

ក្តារចុចលើអក្រង់មាននៅលើកុំព្យូទ័រ និងថេប្លេតស្ទើរតែទាំងអស់។ ទោះយ៉ាងណាក៏ដោយ ពួកវាត្រូវបានប្រើនៅក្នុងឧបករណ៍អក្រង់ប៉ះដូចជាថេប្លេត និងកុំព្យូទ័រ All-in-one ។ អ្នកអាចប្រើសម្រាប់ចុចដោយប្រើម៉ៅ ឬដោយប៉ះគ្រាប់ចុចនៅលើអក្រង់ប៉ះ។

ប្រភេទនៃការភ្ជាប់ក្តារចុច

ក្តារចុចអាចភ្ជាប់ជាមួយកុំព្យូទ័ររបស់អ្នកជាមួយខ្សែ (ខ្សែ) ឬប្រើសញ្ញាឥតខ្សែ (ឥតខ្សែ) ។

ខ្សែ

ក្តារចុចមានខ្សែត្រូវបានភ្ជាប់ទៅកុំព្យូទ័ររបស់អ្នកដោយប្រើខ្សែ (ជាទូទៅ USB) ហើយមិនត្រូវការប្រភពថាមពលបន្ថែមដូចជាថ្មទេ។

ឥតខ្សែ

ក្តារចុចឥតខ្សែប្រើប្រហែងវិទ្យុ (RF) ឬប៊ូទូស (BT) ដើម្បីភ្ជាប់ទៅកុំព្យូទ័ររបស់អ្នក។ បញ្ហាខ្សែរាយប៉ាយត្រូវបានកាត់បន្ថយ និងផ្តល់ឱ្យអ្នកនូវភាពបត់បែនក្នុងការប្រើក្តារចុចពីចម្ងាយពីរបីម៉ែត្រពីកុំព្យូទ័រ។ ក្តារចុចប៊ែបនេះតម្រូវឱ្យប្រើថ្មដើម្បីដំណើរការ។

ក្តារចុងដែលប្រើបច្ចេកវិជ្ជា RF ជាធម្មតាភ្ជាប់ជាមួយឧបករណ៍ទទួលដែលអ្នកត្រូវភ្ជាប់ទៅកុំព្យូទ័ររបស់អ្នក។ ក្តារចុចប៊ូទូសអាចភ្ជាប់ជាមួយកាតប៊ូទូសដែលភ្ជាប់ជាមួយកុំព្យូទ័ររបស់អ្នក ឬអាចប់ទ័រប៊ូទូសខាងក្រៅ។

ស្តាកសេវាកម្ម និងលេខកូដសេវាកម្មរហ័ស

អ្នកអាចស្វែងរកស្តាកសេវាកម្ម និងលេខកូដសេវាកម្មរហ័សនៃកុំព្យូទ័ររបស់អ្នកដូចខាងក្រោម៖

- ស្តាកលើកុំព្យូទ័រ ឬថេប្លេត
- SupportAssist នៅលើកុំព្យូទ័ររបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែមសូមមើល Dell SupportAssist ។
- គេហទំព័រជំនួយរបស់ Dell www.dell.com/support ។
- កម្មវិធីដំឡើង BIOS

ស្វែងរកទីតាំងស្តាកនៅលើកុំព្យូទ័ររបស់អ្នក

កុំព្យូទ័រយួរដៃ—នៅខាងក្រោមកុំព្យូទ័រយួរដៃក្រោមស្តាកប្រព័ន្ធ ឬនៅក្នុងថ្ម

កុំព្យូទ័រលើតុ—នៅផ្នែកខាងក្រោយ ឬខាងលើនៃគ្រឿងកុំព្យូទ័រ

ថេប្លេត—នៅខាងក្រោយ ឬក្រោមថេប្លេត

ចំណាំ: សម្រាប់ព័ត៌មានបន្ថែមអំពីទីតាំងនៃស្តាកសញ្ញានៅលើឧបករណ៍របស់អ្នក សូមមើល *Quick Start Guide (ការណែនាំចាប់ផ្តើមរហ័ស)* ដែលបានភ្ជាប់មកជាមួយកុំព្យូទ័ររបស់អ្នក ឬមើល *Setup and Specifications (ការដំឡើង និងលក្ខណៈបច្ចេកទេស)* តាមរយៈ www.dell.com/support ។

គេហទំព័រគាំទ្ររបស់ Dell

1. ចូលមើលគេហទំព័រ www.dell.com/support។
2. ចុច ឬប៉ះ **Detect Product (ស្វែងរកផលិតផល)** និងអនុវត្តតាមការណែនាំនៅលើអេក្រង់។

កម្មវិធីដំឡើង BIOS

1. បើក ឬចាប់ផ្តើមកុំព្យូទ័ររបស់អ្នកឡើងវិញ ។
2. នៅពេលដែលឃើញសញ្ញា DELL លេចឡើង សូមមើលការស្នើសុំដើម្បីវាយ F2 លេចឡើង ហើយបន្ទាប់មកចុច F2 ភ្លាមដើម្បីបញ្ចូលកម្មវិធីដំឡើង BIOS ។

   ចំណាំ: ការស្នើសុំដើម្បីវាយ F2 លេចឡើងតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ ប្រសិនបើអ្នកខកខានចំពោះការស្នើសុំ, សូមរង់ចាំកុំព្យូទ័ររបស់អ្នកដើម្បីប៊ូតចូលទៅប្រព័ន្ធប្រតិបត្តិការហើយបន្ទាប់មកបិទកុំព្យូទ័ររបស់អ្នកហើយព្យាយាមម្តងទៀត។
3. សូមទៅកាន់ផេប **Main (សំខាន់)** និងស្វែងរក **Service Tag (ស្តាកសេវា)** ។ សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីដំឡើង BIOS សូមមើល Service Manual (សៀវភៅសេវាកម្ម) នៃកុំព្យូទ័ររបស់អ្នកតាមរយៈ www.dell.com/support ។

ឧបករណ៍ផ្ទុក

ឧបករណ៍ផ្ទុកទិន្នន័យអនុញ្ញាតឱ្យអ្នកផ្ទុកទិន្នន័យសម្រាប់ប្រើពេលក្រោយ។ ឧបករណ៍ផ្ទុករាចជាខាងក្នុង ឬខាងក្រៅ។ ឧបករណ៍ផ្ទុកភាគច្រើនរក្សាទុកទិន្នន័យរហូតដល់អ្នកលុបទិន្នន័យដោយដៃ។ ឧទាហរណ៍នៃឧបករណ៍ផ្ទុកគឺមានដ្រាយថាសរឹង (HDD) ដ្រាយស្ថានភាពរឹង (SSD) ដ្រាយអុបទិក ហ្លាសដ្រាយ ជាដើម។

ឧបករណ៍ផ្ទុកខាងក្នុង

ឧបករណ៍ផ្ទុកខាងក្នុងត្រូវបានដំឡើងនៅលើកុំព្យូទ័ររបស់អ្នក និងជាទូទៅមិនអាចយកចេញបានទេ ខណៈដែលកុំព្យូទ័របើកដំណើរការ។ ឧបករណ៍ផ្ទុកខាងក្នុងដែលទូទៅបំផុតគឺដ្រាយថាសរឹង—HDDs និងដ្រាយស្ថានភាពរឹង—SSDs។ HDDs និង SSDs ប្រើប្រាស់ចំនុសប្រចាក់ SATA ដើម្បីផ្ទេរព័ត៌មាន។ SSDs ក៏មានសណ្ឋានស្រដៀងគ្នានឹង HDDs ដែរ ដែលធ្វើឱ្យវាត្រូវគ្នាជាមួយកុំព្យូទ័រដែលមានស្រាប់។ HDDs មានទុំផុតបន្ទះថាស។ SSDs ប្រើប្រាស់អង្គចងចាំហ្លាសដែលធ្វើឱ្យ SSDs មានល្បឿនលឿនជាង ដំណើរការស្ងាត់ជាង ប្រើប្រាស់ថាមពលតិចជាង និងធន់នឹងការរង្គើ។

ឧបករណ៍ផ្ទុកចល័តដែលអាចដកចេញបាន

ឧបករណ៍ផ្ទុកដែលអាចត្រូវបានដកចេញពីកុំព្យូទ័ររបស់អ្នកដោយមិនចាំបាច់បិទកុំព្យូទ័ររបស់អ្នកហៅថាឧបករណ៍ផ្ទុកចល័តដែលអាចដកចេញបាន។ ការប្រើឧបករណ៍ផ្ទុកចល័តដែលអាចដកចេញបាន ជាទូទៅរួមមាន៖

- ឌីសអុបទិក
- កាតអង្គចងចាំ
- ហ្លាសដ្រាយ
- ដ្រាយថាសរឹងខាងក្រៅ

ដ្រាយអុបទិក និងឌីស

កុំព្យូទ័ររបស់អ្នកអាចមានដ្រាយ DVD RW ឬ DVD RW រួមជាមួយ Blu-ray។ ឌីសអុបទិកអាចអានតែប៉ុណ្ណោះ ចម្លងបានតែម្តង ឬអាច ចម្លងបានឡើងវិញ។ ប្រភេទទូទៅមួយចំនួនៃដ្រាយគឺ៖

- ឧបករណ៍ថតចម្លង Blu-ray - អាន និងថតចម្លងទៅឌីស Blu-ray ឌីវីឌី និងស៊ីឌី។
- ឧបករណ៍អាន Blu-ray + DVD RW បញ្ចូលគ្នា—អានឌីស Blu-ray ។ អាន និងសរសេរទៅក្នុងឌីវីឌី និងស៊ីឌី។
- DVD RW-អាន និងសរសេរទៅកាន់ឌីវីឌី និងស៊ីឌី។

កាតអង្គចងចាំ

កាតអង្គចងចាំក៏ត្រូវបានគេហៅថាមេឌៀ ឬកាតហ្វាស ប្រើអង្គចងចាំហ្វាសដើម្បីរក្សាទុកទិន្នន័យ។ ហ្វាសទាំងនោះអាចសរសេរបានរាប់ម៉ាស និងរក្សាទុកទិន្នន័យសូម្បីតែនៅពេលដែលការផ្គត់ផ្គង់ថាមពលត្រូវបានកាត់ផ្តាច់ក៏ដោយ។ ពួកវាជាទូទៅគេប្រើនៅក្នុងឧបករណ៍អ្វូចជាកាមេរ៉ាឌីជីថល ទូរស័ព្ទដៃ ឧបករណ៍ចាក់តន្ត្រី ប្រព័ន្ធកម្សាន្តហ្គេមជាដើម។ កុំព្យូទ័ររបស់អ្នកអាចមានកម្មវិធីអានកាតមេឌៀដើម្បីអាន និងសរសេរទៅកាន់កាតទាំងនេះ។

ប្រភេទកាតអង្គចងចាំទូទៅមួយចំនួនមាន៖

តារាង 1. ឧទាហរណ៍នៃប្រភេទកាតទូទៅ

Secure Digital (SD)/ Secure Digital High Capacity (SDHC)	
Secure Digital Extended Capacity (SDXC) [កាតជាមួយ Ultra High Speed (UHS, ល្បឿនលឿនក្រៃលែង)]	
Secure Digital miniSD	
Multimedia Card (MMC, កាតពហុមេឌៀ)	
MultiMedia Card plus (MMC+, កាតពហុមេឌៀបន្ថែម)	
MultiMedia Card (MMC) Mobile (កាតពហុមេឌៀចល័ត)	

តារាង 1. ឧទាហរណ៍នៃប្រភេទកាតទូទៅ

RS MMC	
Extreme Digital (xD)	
Memory Stick XC (MSXC)	
Compact Flash I, II/Compact Flash MD	
Memory Stick Duo	
Memory Stick Pro Duo	
Memory Stick Pro-HG Duo	
Memory Stick (MS)/Memory Stick Pro (MS Pro)	
មេម៉ូរីកាតដ៍/មេម៉ូរីកាតដ៍ XD	

ម៉ូឌុលអង្គចងចាំ

ម៉ូឌុលអង្គចងចាំ ផ្តុកទិន្នន័យបណ្តោះអាសន្នដែលកុំព្យូទ័ររបស់អ្នកត្រូវការដើម្បីបំពេញកិច្ចការ។ ឯកសារ ឬកម្មវិធីណាមួយ ផ្តុកនៅក្នុងម៉ូឌុលអង្គចងចាំ មុនពេលអ្នកអាចបើក ឬប្រើវា។ ម៉ូឌុលអង្គចងចាំ ត្រូវបានចាត់ថ្នាក់ទៅតាមសមត្ថភាព (គិតជា GB) និងល្បឿន (គិតជា MHz)។ ចំនួនអង្គចងចាំកាន់តែរហ័ស និងខ្ពស់ ជាទូទៅផ្តល់ផលិតផលការងារកាន់តែប្រសើរ។ ប្រភេទម៉ូឌុលអង្គចងចាំទូទៅមាន៖

- **Dual In-line Memory Module (DIMM, ម៉ូឌុលអង្គចងចាំក្នុងបណ្តាញទូទៅ)**—ត្រូវបានប្រើនៅក្នុងកុំព្យូទ័រលើតុ។
- **Small Outline Dual In-line Memory Module (SODIMM, ម៉ូឌុលអង្គចងចាំក្នុងបណ្តាញទូទៅតូចជាង)**—មានទំហំតូចជាង DIMMs។ ជាទូទៅត្រូវបានប្រើនៅក្នុងកុំព្យូទ័រយួរដៃ។ ទោះជាយ៉ាង SODIMM ក៏អាចត្រូវបានប្រើនៅក្នុងកុំព្យូទ័រលើតុ និងកុំព្យូទ័រ All-in-one ។

ផ្ទាំងប្រព័ន្ធ

ផ្ទាំងប្រព័ន្ធបង្កើតជាផ្នែកកណ្តាលនៃកុំព្យូទ័រ។ ឧបករណ៍ផ្សេងទៀតទាំងអស់ភ្ជាប់ទៅផ្ទាំងប្រព័ន្ធដើម្បីអាចទាក់ទងគ្នាទៅវិញទៅមកបាន។ ផ្ទាំងប្រព័ន្ធគ្រប់គ្រងឧបករណ៍បញ្ជា និងឧបករណ៍ភ្ជាប់ផ្សេងៗដែលជួយក្នុងការផ្លាស់ប្តូរទិន្នន័យក្នុងចំណោមសមាសធាតុផ្សេងៗនៃកុំព្យូទ័រ។ ផ្ទាំងប្រព័ន្ធក៏មានបញ្ចូលក្រាហ្វិក សំឡេង និងសមត្ថភាពបណ្តាញផងដែរ។ សមាសធាតុសំខាន់ៗមួយចំនួនរបស់ផ្ទាំងប្រព័ន្ធរួមមាន៖

- រន្ធអង្គដំណើរការ
- ឧបករណ៍ភ្ជាប់ម៉ូឌុលអង្គចងចាំ
- រន្ធដោតកាតបន្ថែម
- CMOS ដើម្បីរក្សាទុក BIOS

សំណុំបន្ទះសៀគ្វីតូច

សំណុំបន្ទះសៀគ្វីតូចគ្រប់គ្រងផ្នែកផ្សេងៗនៅលើផ្ទាំងប្រព័ន្ធ និងបើកការទំនាក់ទំនងរវាងផ្នែកផ្សេងៗ។ ជាទូទៅ សំណុំបន្ទះសៀគ្វីតូចគឺជាផ្នែកនៃផ្ទាំងប្រព័ន្ធ។ ទោះជាយ៉ាងណា ជាមួយអង្គដំណើរការជំនាន់ថ្មីមួយចំនួន សំណុំបន្ទះសៀគ្វីតូចអាចត្រូវបានរួមបញ្ចូលនៅក្នុងអង្គដំណើរការវិតម្តង។

អង្គដំណើរការ

អង្គដំណើរការទទួលទិន្នន័យ និងការណែនាំពីកម្មវិធី និងដំណើរការទិន្នន័យដែលបានស្នើសុំពីសូហ្វវែរ។ អង្គដំណើរការត្រូវបានបង្កើតឡើងជាពិសេសសម្រាប់កុំព្យូទ័រលើតុ កុំព្យូទ័រយួរដៃ ឧបករណ៍ចល័ត ។ ល។ ជាទូទៅអង្គដំណើរការត្រូវបានបង្កើតឡើងសម្រាប់ប្រភេទឧបករណ៍តែមួយប្រភេទ ហើយមិនអាចប្រើនៅលើប្រភេទឧបករណ៍ផ្សេងទៀតបានទេ។ អង្គដំណើរការបង្កើតឡើងសម្រាប់កុំព្យូទ័រយួរដៃ និងឧបករណ៍ចល័ត ប្រើថាមពលតិចបើប្រៀបធៀបទៅនឹងអង្គដំណើរការដែលបង្កើតឡើងសម្រាប់កុំព្យូទ័រលើតុ ឬម៉ាស៊ីនបម្រើ។



គេចាត់ថ្នាក់អង្គដំណើរការដោយផ្អែកលើចំណុចសំខាន់ៗ៖

- ចំនួន cores ដំណើរការ
- ល្បឿន ឬប្រហែលដែលវាស់វែងនៅក្នុង GigaHertz (GHz) ឬ MegaHertz (MHz)
- អង្គចងចាំនៅលើផ្ទាំង ឬឃាថាជាឃ្នាំងសម្ងាត់

ទិដ្ឋភាពទាំងនេះកំណត់ពីដំណើរការនៃអង្គដំណើរការផងដែរ។ តម្លៃខ្ពស់ជាងជាទូទៅមានន័យថាមានដំណើរការល្អ។ អង្គដំណើរការខ្លះមានឃាក់បញ្ចូលនៅលើផ្ទាំងប្រព័ន្ធ។ ក្រុមហ៊ុនផលិតអង្គដំណើរការមួយចំនួន មានដូចជាក្រុមហ៊ុន Intel, AMD, Qualcomm ។ល។

កង្ហារកុំព្យូទ័រ

កង្ហារកុំព្យូទ័រធ្វើឱ្យសមាសធាតុខាងក្នុងរបស់កុំព្យូទ័រមានភាពត្រជាក់ដោយបណ្តេញខ្យល់ក្តៅចេញពីកុំព្យូទ័រ។ ជាទូទៅកង្ហារកុំព្យូទ័រត្រូវបានគេប្រើដើម្បីធ្វើឱ្យសមាសធាតុត្រជាក់ចំពោះឧបករណ៍មានថាមពលខ្ពស់ហើយបង្កើតកំដៅខ្លាំង។ រក្សាសមាសធាតុឱ្យត្រជាក់ជួយក្នុងការការពារពីការឡើងកំដៅ មិនដំណើរការ និងកំហុស។

កន្លែងទទួលកំដៅ

កន្លែងទទួលកំដៅត្រូវបានប្រើដើម្បីបំភាយកំដៅដែលបង្កើតដោយអង្គដំណើរការ កាតក្រាហ្វិកដែលមានគុណភាពខ្ពស់ និងបន្ទុះឈីបលើផ្ទាំង។ កន្លែងទទួលកំដៅជាទូទៅមានកង្ហារមួយដែលដាក់ខាងលើឬនៅក្បែរដើម្បីបង្កើនល់ហូរខ្យល់។ កន្លែងទទួលកំដៅត្រូវបានបង្កើតឡើងដោយ បន្ទះស្តើង។ ជំនួសឱ្យប្លុកដែកតែមួយ។ វាជួយបង្កើនផ្ទៃលើសម្រាប់បំភាយកំដៅ។ ស្រទាប់ការពារកំដៅត្រូវបានដាក់នៅចន្លោះអង្គដំណើរការ ឬកាត ក្រាហ្វិកនិងកន្លែងកំដៅសម្រាប់ផ្លាស់ប្តូរកំដៅឱ្យងាយស្រួល។

ការការពារកំដៅ

ការការពារកំដៅគេហៅថាជាប្រភេទជែល ឬល្បាយកំដៅ ត្រូវបានប្រើដើម្បីបង្កើតស្រទាប់កំដៅរវាងអង្គដំណើរការ និងកង្ហារកំដៅ។ ការដាក់ការការពារកំដៅរវាងអង្គដំណើរការ និងកង្ហារកំដៅ បង្កើនការបញ្ជូនកំដៅពីអង្គដំណើរការទៅកង្ហារកំដៅ ដោយសារការការពារកំដៅនាំកំដៅចេញល្អជាងខ្យល់។

កាតវីដេអូ

កាតវីដេអូដំណើរការទិន្នន័យក្រាហ្វិក និងផ្ទេរទិន្នផលវីដេអូទៅឧបករណ៍បង្ហាញដូចជាអេក្រង់ ឬឧបករណ៍បញ្ចាំង។ កាតវីដេអូអាចមានចំនួនពីរប្រភេទ៖

- **Integrated (រួមបញ្ចូល)**—ជាញឹកញាប់ត្រូវបានស្គាល់ថាជាកាតវីដេអូនៅលើផ្ទាំង វាត្រូវបានរួមបញ្ចូលនៅលើផ្ទាំងប្រព័ន្ធ។ នៅក្នុងកុំព្យូទ័រមួយចំនួន កាតវីដេអូត្រូវបានរួមបញ្ចូលនៅក្នុងអង្គដំណើរការ។ កាតវីដេអូដែលបានរួមបញ្ចូលជាទូទៅចែករំលែកអង្គចងចាំប្រព័ន្ធ (RAM) ហើយក៏អាចប្រើប្រាស់អង្គដំណើរការដើម្បីដំណើរការវីដេអូផងដែរ។

  អង្គដំណើរការដែលបានបង្កើនល្បឿន (APU) ត្រូវបានរួមបញ្ចូលនៅលើអង្គដំណើរការ និងផ្តល់អត្រាផ្ទេរទិន្នន័យខ្ពស់ជាងមុន ខណៈដែលកាត់បន្ថយការប្រើប្រាស់ថាមពល។

- **Discrete (ដាច់)**— កាតវីដេអូដាច់ ត្រូវបានដំឡើងដាច់ដោយឡែកនៅលើផ្ទាំងប្រព័ន្ធ។ កាតវីដេអូដាច់មានអង្គចងចាំដាច់ដោយឡែកនៅលើកាត និងជាទូទៅផ្តល់ប្រសិទ្ធភាពខ្ពស់ជាងកាតវីដេអូដែលត្រូវបានរួមបញ្ចូល។ កាតទាំងនេះ ស័ក្តិសមបំផុតសម្រាប់កម្មវិធីដែលប្រើក្រាហ្វិកខ្លាំង វីដេអូហ្គេមកម្រិតខ្ពស់ និងផ្សេងៗទៀត។

  ចំណាំ: នៅពេលកាតវីដេអូដាច់ ត្រូវបានដំឡើងនៅលើកុំព្យូទ័រ ដែលមានកាតវីដេអូរួមបញ្ចូលដោះ កាត់វីដេអូដែលបានរួមបញ្ចូល ត្រូវបានបិទតាមលំនាំដើម។ ប្រើប្រាស់កម្មវិធីរៀបចំ BIOS ដើម្បីជ្រើសរើសកាតប្រើប្រាស់។

ក្រាហ្វិកដែលអាចផ្លាស់ប្តូរបាន អនុញ្ញាតឱ្យកុំព្យូទ័រដែលមានទាំងកាតក្រាហ្វិករួមបញ្ចូលដែលប្រើថាមពលទាប និងកាតក្រាហ្វិកដាច់ដែលប្រើថាមពលខ្ពស់ ដើម្បីប្តូររវាងកាតទាំងពីរ អាស្រ័យទៅលើបន្ទុកការងារ និងតម្រូវការ។

កម្មវិធីទូរទស្សន៍

អ្នកអាចប្រើកម្មវិធីទូរទស្សន៍ ដើម្បីមើលទូរទស្សន៍នៅលើកុំព្យូទ័ររបស់អ្នកបាន។ កម្មវិធីទូរទស្សន៍អាចប្រើបានជាមួយកុំព្យូទ័រយូអេ និងកុំព្យូទ័រលើតុ ជាឧបករណ៍ដែលមាននៅខាងក្នុង ឬ ខាងក្រៅ។

ចំណាំ: កម្មវិធីទូរទស្សន៍មិនអាចដំណើរការជាមួយកុំព្យូទ័របានទាំងអស់នោះទេ។

ខាងក្នុង៖

- PCI-E
- PCI

ខាងក្រៅ៖

- USB
- កត PC
- ExpressCard

ភាគច្រើនកម្មវិធីទូរទស្សន៍នៅងាយតែឯង ប៉ុន្តែភាគីវីឌីអូខ្លះក៏មានកម្មវិធីទូរទស្សន៍នៅក្នុងស្រាប់។ សម្រាប់ព័ត៌មានបន្ថែមក្នុងការប្រើប្រាស់កម្មវិធីទូរទស្សន៍សូមមើលឯកសាររបស់កម្មវិធីទូរទស្សន៍។

ឧបករណ៍បំពងសំឡេង

កុំព្យូទ័រយួរដៃ និងថេប្លេតមានឧបករណ៍បំពងសំឡេងដែលមានស្រាប់សម្រាប់អូឌីយ៉ូខាងក្រៅ។ កុំព្យូទ័រលើតុក៏មានឧបករណ៍បំពងសំឡេងដែលមានស្រាប់ផងដែរ។ ប៉ុន្តែឧបករណ៍បំពងសំឡេងនោះត្រូវបានប្រើប្រាស់សម្រាប់ប្រាប់ពីបញ្ហា ឬភាពមិនប្រក្រតីប៉ុណ្ណោះ។

អ្នកក៏អាចភ្ជាប់ឧបករណ៍បំពងសំឡេងខាងក្រៅជាមួយកុំព្យូទ័រ ឬថេប្លេតរបស់អ្នកបានផងដែរ។ ឧបករណ៍បំពងសំឡេងអាចប្រើជាមួយឧបករណ៍ភ្ជាប់អូឌីយ៉ូចំហាំ 3.5 mm, USB, ឬប្រព័ន្ធឥតខ្សែទៅនឹងកុំព្យូទ័ររបស់អ្នក។

ជាទូទៅឧបករណ៍បំពងសំឡេងត្រូវបានបែងចែកប្រភេទដោយកំណត់លេខឆានែលអូឌីយ៉ូ ដែលវាដំណើរការបានដូចជា 2, 2.1, 5.1, 7.1។ល។ លេខនៅពីមុខសញ្ញាទសភាគចង្អុលបង្ហាញចំនួនឆានែល និងលេខបន្ទាប់ពីទសភាគបង្ហាញពីឧបករណ៍បំពងសំឡេងតូច។

ចំណាំ: កាតសម្លេង និងឧបករណ៍បំពងសំឡេងរបស់អ្នកត្រូវតែគាំទ្រជាមួយឆានែល 5.1/7.1 សម្រាប់បង្កើតឆានែលអូឌីយ៉ូ 5.1/7.1 ។

2.1 អូឌីយ៉ូ

2.1 សំដៅលើប្រព័ន្ធមួយដែលមានឧបករណ៍បំពងសំឡេងពីរ (ឆានែលខាងឆ្វេង និងស្តាំ) និងឧបករណ៍បំពងសំឡេងតូចមួយ។

អូឌីយ៉ូ 5.1

5.1 សំដៅទៅលើចំនួននៃឆានែលអូឌីយ៉ូនៅក្នុងការកំណត់រចនាសម្ព័ន្ធសំឡេងជុំវិញភាគច្រើនបំផុត។ ប្រព័ន្ធអូឌីយ៉ូ 5.1 ប្រើឆានែលអូឌីយ៉ូប្រាំសំខាន់ៗ (ខាងមុខផ្នែកខាងឆ្វេង ខាងមុខផ្នែកខាងស្តាំ កណ្តាល ក្រោយខាងឆ្វេង និងក្រោយខាងស្តាំ) និងឆានែលអូឌីយ៉ូប្រេកង់ទាបមួយ។

7.1 អូឌីយ៉ូ

7.1 សំដៅទៅលើចំនួនឆានែលអូឌីយ៉ូនៅក្នុងការកំណត់រចនាសម្ព័ន្ធសំឡេងជុំវិញកម្រិតខ្ពស់។ A 7.1 ប្រព័ន្ធអូឌីយ៉ូប្រើឧបករណ៍ចំពងសំឡេងពីរបន្ថែមទៀត (ខាងឆ្វេងផ្នែកខាងក្រោយ និងខាងស្តាំផ្នែកខាងក្រោយ) ដែលរួមបញ្ចូលគ្នាជាមួយប្រព័ន្ធអូឌីយ៉ូ 5.1 ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីការដំឡើងអូឌីយ៉ូ សូមមើល Setting up audio (ការដំឡើងអូឌីយ៉ូ)។

វិបខេម

វិបខេមអាចឲ្យអ្នកថតវីឌីអូ និងរូបភាព និងអាចឲ្យអ្នកទូរស័ព្ទជាវីឌីអូបានផងដែរ។ ធរក្រង់របស់អ្នកអាចមានវិបខេម ឬអ្នកអាចភ្ជាប់វិបខេមខាងក្រៅជាមួយកុំព្យូទ័រអ្នកបាន។ គុណភាពរបស់ការមើលរូបថតវិបខេមអាចផ្តល់ជូនបាន។

ដើម្បីអាចប្រើវិបខេម នោះអ្នកត្រូវតែដំឡើងក្រាយវើវិបខេម និងសូហ្វវែរជាមុនសិន។ ប្រសិនបើអ្នកទិញវិបខេមជាមួយកុំព្យូទ័រ នោះក្រាយវើ និងសូហ្វវែរគឺត្រូវបានដំឡើងរួចជាស្រេចនៅពេលអ្នកទទួលបានកុំព្យូទ័ររបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែមក្នុងការដំឡើងវិបខេម សូមមើល Setting up your webcam (ការដំឡើងវិបខេមរបស់អ្នក)។

បណ្តាញ

បណ្តាញនេះអនុញ្ញាតឲ្យអ្នកភ្ជាប់ឧបករណ៍របស់អ្នកជាមួយគ្នា និងទៅកាន់អ៊ិនធឺណិត។ ឧបករណ៍ទាំងនេះរួមមានកុំព្យូទ័រ ថេប្លេត ទូរស័ព្ទ ម៉ាស៊ីនព្រីន និងឧបករណ៍អេឡិចត្រូនិចដទៃទៀត។ អ្នកអាចដំឡើងបណ្តាញរបស់អ្នកដោយប្រើប្រាស់ (LAN) ឬប្រើឧបករណ៍ឥតខ្សែ (WLAN) ។ បណ្តាញក៏អាចដំឡើងបានដោយប្រើអ៊ីស៊ីរីណិត, Wi-Fi, WWAN, និងបច្ចេកវិជ្ជាដទៃ។

Local Area Network (បណ្តាញតំបន់មូលដ្ឋាន)

ជំនួសអត្ថបទនេះជាមួយខ្លឹមសារបស់អ្នក។ ឧបករណ៍ត្រូវបានតភ្ជាប់ដោយប្រើប្រាស់ខ្សែអ៊ីស៊ីរីណិត និងត្រូបដណ្តប់លើតំបន់ទំហំតូច ជាទូទៅនៅក្នុងគេហដ្ឋាន និងអគារ។

Wireless Local Area Network (បណ្តាញក្នុងតំបន់ឥតខ្សែ)

ឧបករណ៍ត្រូវបានភ្ជាប់ដោយឥតខ្សែ និងត្រូបដណ្តប់តំបន់តូចមួយដែលជាទូទៅនៅក្នុងផ្ទះ ឬអគារមួយ។ ការភ្ជាប់ឥតខ្សែដែលប្រើសម្រាប់ការដំឡើង WLAN ជាទូទៅគឺ Wi-Fi (802.11x ដែល X សំដៅទៅលើពិធីសារ 802.11 ខុសៗគ្នា) ។

Wireless Wide Area Network (បណ្តាញតំបន់ធំទូលាយឥតខ្សែ)

ក៏អាចហៅថាជា Mobile Broadband សេវាកម្មនេះជាទូទៅត្រូវបានផ្តល់ជូនដោយក្រុមហ៊ុនទូរស័ព្ទសម្រាប់ប្រើនៅលើឧបករណ៍ចល័ត។ ឧបករណ៍ចល័ត ឬកុំព្យូទ័រយួរដៃត្រូវដំណើរការជាមួយបច្ចេកវិជ្ជា WWAN ដើម្បីភ្ជាប់បណ្តាញនេះ។

Wireless Personal Area Network (បណ្តាញតំបន់ផ្ទាល់ខ្លួនឥតខ្សែ)

ជាទូទៅ ឧបករណ៍ត្រូវបានតភ្ជាប់គ្នាដោយឥតខ្សែដោយប្រើប្រាស់ Bluetooth, RF, Near-Field Communication (NFC) និងផ្សេងៗទៀត។ ជាទូទៅបណ្តាញប្រភេទនេះប្រតិបត្តិការនៅក្នុងចម្ងាយដែលនៅជិតឧបករណ៍ពីរបីហ្វីត (0.6 ម៉ែត្រ)។ ដើម្បីតភ្ជាប់កុំព្យូទ័រ ឬថេប្លេតទៅអ៊ីនធឺណិត សូមមើល Connecting to the internet (ការតភ្ជាប់ទៅអ៊ីនធឺណិត)។

ម៉ូឌឹម

ម៉ូឌឹមអនុញ្ញាតឲ្យអ្នកភ្ជាប់កុំព្យូទ័រ ឬម៉ាតទ័ររបស់អ្នកទៅអ៊ីនធឺណិត។ ម៉ូឌឹមអាចជាអណាឡុក (dial-up) ឬឌីជីថល (DSL ឬខ្សែ) ។ ម៉ូដឹមដែល DSL ឬខ្សែជាទូទៅត្រូវបានផ្តល់ជូនដោយអ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។

- **ម៉ូដឹម Dial-up** —ឧបករណ៍អេឡិចត្រូនិចដែលបម្លែងសញ្ញាទូរស័ព្ទអណាឡុក ទៅជាសញ្ញាឌីជីថលដែលកុំព្យូទ័រអាចដំណើរការ និងសញ្ញាកុំព្យូទ័រឌីជីថលទៅក្នុងសញ្ញាអណាឡុកដែលអាចបញ្ជូនតាមទូរស័ព្ទបាន។ ម៉ូឌឹម Dial-up អាចជាខាងក្នុង ឬខាងក្រៅ។
- **ម៉ូឌឹមឌីជីថល**—ប្រើដើម្បីផ្ញើ និងទទួលទិន្នន័យទៅនិងមកពីបណ្តាញទូរស័ព្ទឌីជីថលដូចជា Digital Subscriber Line (DSL, បណ្តាញអតិថិជនឌីជីថល) ឬបណ្តាញឌីជីថលសេវាកម្មចម្រុះ (ISDN) ។

ម៉ាទ័រ

ម៉ាទ័រគឺជាឧបករណ៍ដែលបញ្ជូនទិន្នន័យបន្តរវាងបណ្តាញកុំព្យូទ័រ។ ប្រភេទម៉ាទ័រដែលទូទៅបំផុតគឺម៉ាទ័រនៅតាមគេហដ្ឋាន និងការិយាល័យតូចៗ ដែលអនុញ្ញាតឲ្យអ្នកចែករំលែកការតភ្ជាប់អ៊ីនធឺណិត រវាងឧបករណ៍ច្រើនក្នុងពេលតែមួយ។

ម៉ាទ័រអាចប្រើខ្សែ ឬឥតខ្សែ។ ម៉ាទ័រមានខ្សែអនុញ្ញាតឲ្យអ្នកតភ្ជាប់កុំព្យូទ័ររបស់អ្នកដោយប្រើខ្សែអ៊ីនធឺណិត (Ethernet) (RJ45)។ ម៉ាទ័រតាមគេហដ្ឋានដែលប្រើខ្សែភាគច្រើនមានរន្ធចំនួនបួន ដែលអនុញ្ញាតឲ្យតភ្ជាប់រហូតដល់កុំព្យូទ័របួនដង្ហែរទៅអ៊ីនធឺណិតក្នុងពេលតែមួយ។ ម៉ាទ័រឥតខ្សែប្រើប្រាស់បច្ចេកវិទ្យា Wi-Fi ដែលអនុញ្ញាតឲ្យអ្នកតភ្ជាប់ទូរស័ព្ទ ថេប្លេត កុំព្យូទ័រ និងឧបករណ៍ផ្សេងៗទៀតរបស់អ្នកទៅកាន់អ៊ីនធឺណិត។

ម៉ាទ័រឥតខ្សែអាចតភ្ជាប់ទៅឧបករណ៍ច្រើនក្នុងពេលតែមួយ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលឯកសារសម្រាប់ម៉ាទ័ររបស់អ្នក។

Network-Interface Controller (ឧបករណ៍បញ្ជាអន្តរបណ្តាញ)

